I - ទីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ០៦ អនក្រ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីគោលការណ៍ប្រាក់កំរៃគរុកោសល្យ នៃបុគ្គលិកសិក្សា និង បញ្ហាពង្រឹងវិស័យគ្រប់គ្រងនៅរាល់គ្រឹស្ថានសិក្សា
- ផ្អែកតាមសភាពការណ៍ចាំបាច់

សំរេច

មាត្រា ១ .- ត្រូវបានបន្ថែមប្រាក់រៀលចំនួន ២០.០០០ រៀល (ពីរម៉ឺនរៀលគត់) ជាប្រាក់កំរៃគរុកោសល្យលើបៀវត្សបច្ចុប្បន្ន ជូនបុគ្គលិកសិក្សាគ្រប់ជាន់ថ្នាក់ ។

មាត្រា ២ .- ប្រាក់បន្ថែមដែលមានចែងក្នុងមាត្រា ១ ដែលត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៤ តទៅ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះរៀងខ្លួនៗ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ០៧ អនក្រ
ស្ដីពីការប្ដូរឈ្មោះ វិទ្យាស្ថានបច្ចេកទេសកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ

សំរេច

មាត្រា ១ - វិទ្យាស្ថានបច្ចេកទេសកសិកម្ម ត្រូវបានប្ដូរឈ្មោះជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.វ.ភ.ក) សរសេរជាភាសាអង់គ្លេសថា ROYAL UNIVERSITY OF AGRICULTURE (R.U.A)

សរសេរ ជាភាសាបារាំងថា UNIVERSITE ROYALE D'AGRICULTUE (U.R.A) ដែលស្ថិតនៅក្រោម ការគ្រប់គ្រងផ្ទាល់ របស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ ។

មាត្រា ២ .- តួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ត្រូវកំណត់ឡើងវិញអោយបានសមស្រប ។

មាត្រា ៣ .- បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមក ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អនុរដ្ឋលេខាធិការមុខងារសាធារណៈ និង សាកលវិទ្យាល័យធិការ នៃសាកលវិទ្យាល័យ ភូមិន្ទកសិកម្មមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ០៨ អនក្រ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាលស្តីពីការតំលើងប្រាក់បៀវត្ស ២០ ភាគរយ លើបៀវត្សសុទ្ធសាធជូនមន្ត្រីរាជការ កងទ័ព និង នគរបាល

_ តាមសំណើរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ .. តំលើងប្រាក់បៀវត្ស ២០ ភាគរយ លើបៀវត្សសុទ្ធសាធជូន ជនពិការ និង និវត្តជន ។

មាត្រា ២ .. ប្រាក់បៀវត្សដែលតំលើង ២០ ភាគរយនេះ ត្រូវអនុវត្តពីបៀវត្ស ខែ មិនា ឆ្នាំ ១៩៩៤ តទៅ ។

មាត្រា ៣ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុងត្រូវ ទទួលអនុវត្តអនុក្រឹត្យនេះ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ០៩ អនក្រ

ស្តីពីការបង្កើតសេនាធិការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ សៀមរាប . បន្ទាយមានជ័យ. បាត់ដំបង.កំពង់ចាម និង ក្រុងព្រះសីហនុ

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃ ព្រះរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតអគ្គសេនាធិការកងទ័ពជាតិកម្ពុជា
- ផ្អែកតាមសំណូមពរ នៃការកសាងកងរាជអាវុធហត្ថឆ្នាំ ១៩៩៤ និង ដើម្បីបង្កើនការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សង្គម បង្ក្រាបរាល់អំពើល្មើសច្បាប់
- ផ្អែកតាមសំណើររបស់នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

សំរេច

មាត្រា ១ - ត្រូវបានបង្កើតសេនាធិការដ្ឋាន កងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម និង ក្រុងព្រះសីហនុ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់បញ្ជាការដ្ឋានកងអាវុធហត្ថ នៃ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ - រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់សេនាធិការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម និង ក្រុងព្រះសីហនុ អាស្រ័យដោយអគ្គសេនាធិការកំណត់ ។

មាត្រា ៣ - ប្រគល់ជូនអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាជាក់ស្ដែងក្នុង ការរៀបចំសេនាធិការដ្ឋាន កងរាជអាវុធហត្ថខាងលើ ។

មាត្រា ៤ - អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៥ - អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១០ អនក្រ

ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយជាតិកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_ តាមសំណើ របស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ _ បង្កើតទិវាចលនាប្រជាពលរដ្ឋ-ចូលរួមធ្វើហត្ថកម្ម លើការងារធារាសាស្ត្រ ហៅថា "ទិវានយោបាយទឹកកសិកម្ម " ដែលត្រូវប្រារព្ធធ្វើនៅថ្ងៃទី ០៤ មិនាជារៀងរាល់ឆ្នាំ ។

មាត្រា ២ _ ទិសដៅនៃទិវានយោបាយទឹក កសិកម្ម គឺចលនាប្រជារាស្ត្រ កងយោធពលខេមរភូមិន្ទ នគរបាល អ្នករាជការគ្រប់ផ្នែក គ្រប់ថ្នាក់ សិស្ស និស្សិត ដែលមានអាយុ ចាប់ពី ១៨ ឆ្នាំឡើងទៅកំរិត មធ្យមសិក្សា និង ឧត្តម សិក្សាចូលរួមទាំងស្មារតី ទាំងសំភារៈ ក្នុងគោលបំណងដោះស្រាយទឹកដើម្បីបំរើវិស័យកសិកម្ម និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយបានប្រសើរឡើង ។

មាត្រា ៣ _ មន្ត្រី រាជការ ស៊ីវិល កងកំលាំងប្រដាប់អាវុធ និង ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចចូលរួមធ្វើហត្ថកម្ម នេះចំនួន ១៥ ថ្ងៃ ក្នុងមួយឆ្នាំ ដោយគិតចាប់តាំងពីថ្ងៃទី ០៤ មិនា តទៅ ។ ដោយឡែក ចំពោះសិស្ស និស្សិត មានកាតព្វកិច្ចចូលរួមក្នុងរយៈពេល ៧ ថ្ងៃ ។

មាត្រា ៤ _ ក្រសួងមហាផ្ទៃ មានភារកិច្ចណែនាំ អភិបាលខេត្ត-ក្រុង ជ្រើសរើសទីកន្លែងដាក់ស្តែងសំរាប់ការដ្ឋាន និង ចលនាប្រជាពលរដ្ឋចូលរួមព្រមទាំងរៀបចំបំរុងផ្នែកសំភារៈ បំរើអោយចលនានេះទទួលបានប្រសិទ្ធិភាពនយោបាយ និង សេដ្ឋកិច្ចខ្ពស់ ។

មាត្រា ៥ _ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចណែនាំ បច្ចេកទេស និង សហការជាមួយគណៈ កម្មាធិការបុណ្យជាតិ និង បណ្តាខេត្ត-ក្រុង ក្នុងការអនុវត្តន៍ ។

មាត្រា៦ _ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ _ សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការបុណ្យជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន និង អភិបាលខេត្ត-ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២
ព្រះហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ១១ អនក្រ

ស្ដីពីការតែងតាំងអគ្គទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា

ប្រចាំព្រះរាជាណាចក្រថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ស្ដេចក្រុមឃុន ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ _ តែងតាំងឯកឧត្ដម សរ សម្បត្តិ ជាអគ្គទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ